**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៦១៩ ហិកតា និង ៧០ អា នៅស្រុកប្រាសាទបាគង ខេត្តសៀមរាប ចេញពីដីដែលមានដីកាដកហូតលេខ ០៨៥ សសរ របស់ខេត្តសៀមរាប និងគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនយោធិនពិការ និងប្រជាពលរដ្ឋ និងរក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៨ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

ត្រូវបានកាត់ផ្ទៃដីទំហំ ៦១៩ ហិកតា និង ៧០ អា ចេញពីដីដែលមានដីកាដកហូត លេខ ០៨៥ សសរ របស់ខេត្តសៀមរាប និងដីតម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ ៥០៣ ហិកតា និង ៣០ អា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនឃោធិនពិការ និងប្រជាពលរដ្ឋ ដែលបានកាន់កាប់ អាស្រ័យផលជាក់ស្តែង និងដីទំហំ ១១៦ ហិកតា និង ៤០ អា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិស្នារតេជោ ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ខេត្តសៀមរាប តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងនិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើ ៥៥១ ក្បាលដី ជូនប្រជាពលរដ្ឋ ២៧៩ គ្រួសារ នៅភូមិស្នារតេជោ ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១៥ កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ផែនទីនិងតារាងនិយាមការូបសម្ព័ន្ធនៃអនុក្រឹត្យលេខ..១១៣..អនក្រ.បក....ចុះថ្ងៃទី....២០.......ខែ..កក្កដា......ឆ្នាំ២០២០




### តារាងនិយាមការព្រំដី

Projection, UTM, Zone 48N

Datum, WGS,1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 401476.935 | 1488817.482 | 38 | 396219.063 | 1486663.158 |
| 2 | 400442.597 | 1490315.498 | 39 | 396205.118 | 1486660.585 |
| 3 | 400583.448 | 1490357.564 | 40 | 396019.304 | 1486657.530 |
| 4 | 400674.610 | 1490375.787 | 41 | 396863.526 | 1485833.907 |
| 5 | 400727.260 | 1490382.932 | 42 | 400766.518 | 1488494.749 |
| 6 | 400773.029 | 1490386.859 | 43 | 400795.842 | 1488490.186 |
| 7 | 400983.106 | 1490408.958 | 44 | 400816.923 | 1488486.905 |
| 8 | 400961.922 | 1490404.213 | 45 | 400851.419 | 1488490.697 |
| 9 | 400531.120 | 1489724.282 | 46 | 400866.444 | 1488494.669 |
| 10 | 400535.702 | 1489702.889 | 47 | 400905.658 | 1488510.006 |
| 11 | 400526.382 | 1489686.818 | 48 | 400956.043 | 1488537.933 |
| 12 | 400526.372 | 1489671.475 | 49 | 401351.765 | 1488770.087 |
| 13 | 400570.460 | 1489610.292 | 50 | 401403.541 | 1488800.395 |
| 14 | 400589.414 | 1489579.253 | 51 | 401430.811 | 1488810.244 |
| 15 | 400741.676 | 1489579.253 | 52 | 401468.784 | 1488816.139 |
| 16 | 400741.330 | 1488954.299 | 53 | 401481.206 | 1488818.068 |
| 17 | 400594.509 | 1488954.303 | 54 | 401974.275 | 1488796.607 |
| 18 | 400582.946 | 1488945.846 | 55 | 401984.623 | 1488798.710 |
| 19 | 400581.219 | 1488940.437 | 56 | 401992.960 | 1488802.278 |
| 20 | 400583.849 | 1488504.312 | 57 | 401994.822 | 1488803.075 |
| 21 | 400490.356 | 1488381.231 | 58 | 402011.155 | 1488814.731 |
| 22 | 400448.427 | 1488326.898 | 59 | 402631.438 | 1489593.701 |
| 23 | 400404.231 | 1488288.297 | 60 | 402653.280 | 1489607.467 |
| 24 | 400294.755 | 1488270.744 | 61 | 402629.579 | 1489616.810 |
| 25 | 400275.982 | 1488267.728 | 62 | 401557.577 | 1490304.320 |
| 26 | 400319.958 | 1488244.402 | 63 | 401590.963 | 1490301.571 |
| 27 | 400417.481 | 1488260.039 | 64 | 401622.913 | 1490290.891 |
| 28 | 400470.379 | 1488306.240 | 65 | 401630.044 | 1490286.888 |
| 29 | 400608.093 | 1488484.693 | 66 | 401557.271 | 1490805.877 |
| 30 | 400537.190 | 1488199.549 | 67 | 401232.070 | 1490518.093 |
| 31 | 400259.691 | 1488264.640 | 68 | 401173.023 | 1490483.866 |
| 32 | 400170.176 | 1488241.052 | 69 | 400697.649 | 1490380.392 |
| 33 | 400159.894 | 1488238.342 | 70 | 400459.484 | 1490320.695 |
| 34 | 399910.860 | 1488446.622 | 71 | 400490.044 | 1490330.220 |
| 35 | 399902.061 | 1488457.504 | 72 | 400513.062 | 1490336.967 |
| 36 | 399892.611 | 1488458.997 | 73 | 400561.084 | 1490350.461 |
| 37 | 396241.874 | 1486670.399 | 74 | 400538.462 | 1490343.317 |